**មាត្រា ៣** : សាលាភូមិន្ទរដ្ឋបាល ត្រូវបានដឹកនាំដោយមន្ត្រីជាន់ខ្ពស់មួយរូប អមដោយក្រុមប្រឹក្សាភិបាល ។

**មាត្រា ៤** : លក្ខន្តិកៈនៃសាលាភូមិន្ទរដ្ឋបាល ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥** : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦** : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ និងសហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

**មាត្រា ៧** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

**នរោត្តម សីហនុ**

# II-ទីស្តីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៣៨ អនក្រ**

**ស្តីពីមេបន នៃឯកជនភាវូបនីយកម្ម**

**សហគ្រាសសាធារណៈ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤

- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ០១នស ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ១០នស ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៤
- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា១** : សមិទ្ធកម្មនៃកិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្មសហគ្រាស និងទ្រព្យសកម្មសាធារណៈផ្សេងទៀត ដូចដែលបានកំណត់ក្នុងមាត្រា ៨១ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ត្រូវបានសំរេចទៅតាមបែបបទ ដែលបានកំណត់ដោយអនុក្រឹត្យ នេះ ។

**មាត្រា ២** : ត្រូវបានស្ថិតនៅក្រៅដែនអនុវត្ត នៃបទបញ្ញានេះ រួមមានសកម្មភាពទាំងឡាយដែលទាក់ទងទៅនឹងការការពារ និងសន្តិសុខហើយនិងបេតិកភ័ណ្ឌវប្បធម៌ ។

**មាត្រា ៣** : ការងារឯកជនភាវូបនីយកម្មសហគ្រាស និងទ្រព្យសកម្មសាធារណៈត្រូវបានអនុវត្តដោយអនុលោមទៅតាមទិសដៅជាមូលដ្ឋាន នៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ព្រះរាជាណាចក្រកម្ពុជា ជាអាទិ៍សំដៅ :

- លើកស្ទួយអភិក្រមពង្រឹងសេដ្ឋកិច្ចទីផ្សារ និងពង្រឹងផ្នែកឯកជន ។
- លើកកំពស់ការស្តារឡើងវិញ និងអភិវឌ្ឍន៍ប្រព័ន្ធផលិតកម្មរបស់ប្រទេសជាតិ ។
- លើកកំពស់ស្មារតីប្រជាពលរដ្ឋលើបញ្ហាសហគ្រាស និងការទាក់ទាញការបង្កើតវិនិយោគទុនក្រៅប្រទេស ។

**មាត្រា ៤** កិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្មគឺជាកម្មវត្ថុមួយដែលត្រូវបានសំរេចដោយគណៈរដ្ឋមន្ត្រីតាមសំណើរបស់ក្រសួងអាណាព្យាបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

កម្មវិធីដូចបានពោលនេះកំណត់ច្បាស់លាស់នូវបញ្ជីចំនួនសហគ្រាស និងទ្រព្យសកម្ម ដែលត្រូវធ្វើឯកជនភាវូបនីយកម្ម ប្រតិទិនសំរាប់ដាក់អនុវត្តនិតិវិធីប្រតិបត្តិការ និងវិធីធ្វើឯកជនភាវូបនីយកម្ម ។

កម្មវិធីឯកជនភាវូបនីយកម្មត្រូវបានអនុវត្តក្រោមការត្រួតពិនិត្យរបស់គណៈកម្មាធិការឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ដែលបានបង្កើតឡើងដោយមាត្រា ៨២នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ។

**ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ**

**ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ**

**មាត្រា ៥** : គណៈកម្មាធិការមានសមត្ថកិច្ចដូចតទៅ ÷

- រៀបចំគំរោង នៃកម្មវិធីឯកជនភាវូបនីយកម្ម
- ចងក្រងយុទ្ធសាស្ត្រអនុវត្ត និងគំនូសបំព្រួញនៃការងារឯកជនភាវូបនីយកម្ម
- ពិនិត្យឡើងវិញនូវកិច្ចប្រតិបត្តិការត្រៀមបំរុងសំរាប់ឯកជនភាវូបនីយកម្មជាអាទិ៍ គឺអ្វីដែលពាក់ព័ន្ធនឹងការវាយតំលៃទ្រព្យសកម្ម ការបញ្ជាក់លក្ខន្តិកៈគតិយុត្តិនៃទ្រព្យសកម្ម ឬសហគ្រាស ការជំរះបំណុល និងឥណទេយ្យ និងផែនការកាត់បន្ថយចំនួនបុគ្គលិកក្នុងករណីចាំបាច់ ។
- អនុម័តលើចំណុចសំខាន់ៗ ជាគតិយុត្តិ នៃកិច្ចការជំនួញជាអាទិ៍ កិច្ចសន្យា និងសៀវភៅបន្ទុករបស់ឯកជនភាវូបនីយកម្ម ។
- ត្រួតពិនិត្យភាពទៀងទាត់ នៃនិតិវិធីឯកជនភាវូបនីយកម្មជាអាទិ៍ ការប្រកាសដេញថ្លៃ ការពិនិត្យកិច្ចសន្យាទទួលការ និងការជ្រើសរើសយកលទ្ធជន ។

**មាត្រា ៦** : គណៈកម្មាធិការឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈមានសមាសភាពដូចតទៅ ÷

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង | ប្រធាន |
| - សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬតំណាង | សមាជិក |

- រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន ឬតំណាង សមាជិក
- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង សមាជិក
- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬតំណាង សមាជិក
- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ឬតំណាង សមាជិក
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬតំណាង សមាជិក
- ទេសាភិបាលធនាគារជាតិនៃកម្ពុជា ឬតំណាង សមាជិក
- រដ្ឋមន្ត្រីអាណាព្យាបាល ឬតំណាង សមាជិក
- ប្រធានសហគ្រាសដែលមានការពាក់ព័ន្ធតាមការពិភាក្សាសំរេចព្រមទាំងបុគ្គលដទៃទៀតតាមការចាំបាច់ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធានាអោយមានលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការព្រមទាំងការកេណ្ឌមធ្យោបាយមនុស្ស និងសំភារៈចាំបាច់សំរាប់ដំណើរការគណៈកម្មាធិការ ។

**មាត្រា ៧** : គណៈកម្មាធិការឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈក្តាប់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬដោយរដ្ឋមន្ត្រីអាណាព្យាបាល ។ គណៈកម្មាធិការនេះត្រូវធ្វើការប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ។

**មាត្រា ៨** : សេចក្តីសំរេចទាំងឡាយស្តីពីឯកជនភាវូបនីយកម្មត្រូវបានប្រកាសដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់គណៈកម្មាធិការឯកជនភាវូបនីយកម្មសហគ្រាស សាធារណៈ ។

## វិធានការនៃនីតិវិធី

**មាត្រា ៩** :- រាល់កិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្ម ដែលធ្វើឡើងដោយអាណាព្យាបាលសហគ្រាសត្រូវកសាងសំណុំឯកសារមួយ ដើម្បីឆ្លងមតិយោបល់យល់ព្រមពីគណៈកម្មាធិការឯកជនភាវូបនីយកម្ម ។

សំណុំឯកសាររួមមានដូចតទៅ :

- កំណត់បង្ហាញសហគ្រាស
- គំរោងសៀវភៅបន្ទុកនៃឯកជនភាវូបនីយកម្ម

- តំនួសបំព្រួញនៃឯកជនភាវូបនីយកម្មដែលបានស្នើឡើង

**មាត្រា១០** :- តំនួសបំព្រួញនៃឯកជនភាវូបនីយកម្ម ដែលបានរក្សាទុកត្រូវសមស្របនឹងទំហំរបស់សហគ្រាស និងប្រភេទនៃសកម្មភាព ដែលមានការពាក់ព័ន្ធ ។ ទៅតាមករណីតំនួសបំព្រួញទាំងឡាយនៃឯកជនភាវូបនីយកម្មទាំងមូល ឬមួយចំណែកសម្បទាន ឬអនុប្បទានទ្រព្យសកម្មដោយឡែកអាចត្រូវបានរក្សាទុកសំរាប់ការផ្ទេរសហគ្រាស និងទ្រព្យសកម្មសាធារណៈផ្សេងទៀតទៅអោយផ្នែកឯកជន ។

**មាត្រា១១** :- កិច្ចការជំនួញដែលបានអនុវត្តក្នុងក្របខ័ណ្ឌនៃកិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្មមួយត្រូវបានសំរេចតាមរយៈការដេញថ្លៃផ្ទាល់មាត់ក្រោយពីការផ្សព្វផ្សាយដ៏ទូលំទូលាយ ។ ប្រសិនបើក្នុងករណីដែលការដេញថ្លៃមិនបានសំរេចផលទេ ដោយមានការកត់សំគាល់ត្រឹមត្រូវនោះគេអាចត្រឡប់មកនីតិវិធីស្រុះស្រួលគ្នាវិញ ។

**មាត្រា១២** :- ក្នុងករណីដេញថ្លៃ ឬពិគ្រោះថ្លៃ ការបើកស្រោមសំបុត្រ និងកិច្ចសន្យាទទួលការត្រូវប្រព្រឹត្តទៅដោយគណៈកម្មាធិការមួយដែលមានសមាសភាពកំណត់ដោយអនុក្រឹត្យ ។ លទ្ធផលនៃការដេញថ្លៃត្រូវបានកត់ទុកក្នុងរបាយការណ៍សំងាត់ ហើយប្រធានគណៈកម្មាធិការដេញថ្លៃនេះ ត្រូវបង្ហាញដោយផ្ទាល់ទៅគណៈកម្មាធិការភាវូបនីយកម្មសហគ្រាសសាធារណៈ ។

**មាត្រា១៣** :- ដើម្បីធ្វើអោយបានសំរេចកិច្ចប្រតិបត្តិការ ដែលបានកំណត់ក្នុងមាត្រា១០ខាងលើជាបឋមគប្បីចាត់និតិវិធីវាយតំលៃសហគ្រាស ឬទ្រព្យសកម្ម ដែលជាមុខសញ្ញានៃឯកជនភាវូបនីយកម្ម ។

ការវាយតំលៃនេះត្រូវបានធ្វើឡើងដោយអ្នកជំនាញការឯករាជ្យ ដែលមានការតែងតាំងពីអាណាព្យាបាលសហគ្រាស ។ ការតែងតាំងនេះត្រូវបានទទួលការឯកភាពពីគណៈកម្មាធិការឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ។

**មាត្រា ១៤** :- កិច្ចប្រតិបត្តិការទាំងអស់ដែលទាក់ទង នឹងឯកជនភាវូបនីយកម្ម ចាប់តាំងពីការវាយតំលៃសហគ្រាសរហូតដល់ការសំរេចកិច្ចសន្យាលក់ ត្រូវធ្វើតាម លក្ខការណ៍សំងាត់បំផុត ។ អ្នកធ្វើអន្តរាគមន៍ត្រូវប្រកាន់ជំហរអោយបានត្រឹម

ត្រូវតាមគោលការណ៍នេះ បើពុំនោះទេត្រូវទទួលពិន័យដែលបានកំណត់តាមច្បាប់ជាធរមាន ។

**មាត្រា១៥** :- រាល់កិច្ចប្រតិបត្តិការ នៃឯកជនភាវូបនីយកម្ម ត្រូវបង្កើតសៀវភៅបន្ទុកមួយ ដែលរៀបចំឡើងក្រោមការទទួលខុសត្រូវ នៃអាណាព្យាបាលរបស់សហគ្រាសពាក់ព័ន្ធ ហើយដាក់ជូនគណៈកម្មាធិការឯកជនភាវូបនីយកម្ម ដើម្បីសុំការយល់ព្រម ។

**មាត្រា ១៦** :- សៀវភៅបន្ទុកបញ្ជាក់ច្បាស់លាស់នូវលក្ខខ័ណ្ឌឯកជនភាវូបនីយកម្មជាអាទិ៍ ដូចជាបែបបទទូទាត់ និងមូលដ្ឋានហិរញ្ញវត្ថុ និងមុខរបរនៃលទ្ធជន ។ សៀវភៅបន្ទុកអាចមានផងដែរ នូវបញ្ញត្តិមួយចំនួនស្តីពីនិរន្តភាព នៃសកម្មភាពកម្មវិធីវិនិយោគ ឬការរក្សានូវកំរិតការងារមួយដ៏សមស្រប ។

**មាត្រា១៧** :- បើសិនសកម្មភាពដែលមានលក្ខណៈផ្តាច់មុខ ឬជាសេវាកម្មសាធារណៈ នោះសៀវភៅបន្ទុកត្រូវបញ្ជាក់អោយច្បាស់ជាចាំបាច់នូវលក្ខណៈសកម្មភាពនៃអាជីវកម្មដើម្បីជៀសវាងការទាញយកផលប្រយោជន៍ដ៏ហួសហេតុពីភាពផ្តាច់មុខ ពីការខ្វះចន្លោះនៃច្បាប់សាធារណៈ ។

## ការចូលរួមបៀវត្សរ៍ជន និងវិនិយោគិនក្រៅប្រទេស

**មាត្រា១៨** :- អត្ថប្រយោជន៍ពិសេសអាចត្រូវបានផ្តល់អោយនិយោជិក និងក្របខ័ណ្ឌបេក្ខជនទាំងឡាយដែលធ្វើលទ្ធកម្ម(ទិញ) សហគ្រាសរបស់ខ្លួន ឬមួយចំណែកណានោះនៃទ្រព្យសកម្មរបស់ខ្លួន ។

អត្ថប្រយោជន៍ទាំងនេះ ដែលត្រូវបានយល់ព្រមពីគណៈរដ្ឋមន្ត្រី លើសំណើរបស់គណៈកម្មាធិការឯកជនភាវូបនីយកម្មអាចផ្តល់ជាអាទិភាព នូវសិទ្ធិលទ្ធកម្មសហគ្រាស ឬទ្រព្យសកម្មសមស្របជាយថាហេតុ និងជាលក្ខណៈពិសេសនៃថ្លៃ និងរយៈពេលនៃការទូទាត់ ។

**មាត្រា១៩** :- តាមលក្ខខ័ណ្ឌ នៃបទបញ្ញត្តិអាស្រ័យដោយរដ្ឋធម្មនុញ្ញ និងនិត្យានុកូលស្តីពីកម្មសិទ្ធិដីធ្លីរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាបរទេស និវាសជន ឬមិនមែននិវាសជនអាចចូលរួមចំណែកចំពោះកិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្មនេះបានដែរ ។

បទបញ្ញត្តិទាំងឡាយនៅក្នុងមាត្រា ១៦ នៃព្រះរាជក្រមលេខ ០៣ នស ចុះថ្ងៃទី ៥ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការវិនិយោគអាចអនុវត្តបានចំពោះកិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្ម ។

**មាត្រា ២០** :- កិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្ម ដែលបានអនុវត្តនៅក្នុងក្របខ័ណ្ឌនៃអនុក្រឹត្យនេះ ត្រូវបានជ្រើសតាំងទៅតាមអត្ថប្រយោជន៍ ដែលបានចែងក្នុងព្រះរាជក្រមលេខ ០៣ នស ចុះថ្ងៃទី ៥ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីវិនិយោគត្រឹមត្រូវតាមបែបបទដែលបានចែងដោយច្បាប់ដូចដែលបានពោលខាងលើ និងអត្ថបទក្រោយៗទៀត ។

**អវសានប្បញ្ញត្តិ**

**មាត្រា ២១** :- ចំណូលដែលបានមកពីការធ្វើឯកជនភាវូបនីយកម្មនៃសហគ្រាស និងទ្រព្យសកម្ម សាធារណៈផ្សេងទៀត ត្រូវបញ្ចូលទៅក្នុងគណនីពិសេសមួយនៅរតនាគារស្របតាមបទបញ្ញត្តិទាំងឡាយ ដែលបានចែងក្នុងមាត្រា ៨៣ ដល់ ៨៦ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ។

**មាត្រា ២២** :- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៣** :- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី១** | **នាយករដ្ឋមន្ត្រីទី២** |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៥

# អនុក្រឹត្យលេខ ៤៥ អនក្រ